# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ថ្ងៃកាត់ទោសមេគុកទួលស្លែង គឺជារបត់ដ៏សំខាន់មួយសម្រាប់កម្ពុជា

ឆាំង យុ
នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ថ្ងៃ៣០ មីនា ២០០៩ គឺជាចំណុចរបត់មួយរបស់ប្រទេសកម្ពុជា ។ ថ្ងៃនេះក្រោយពីបានរង់ចាំអស់រយៈពេល៣០ឆ្នាំ ប្រជាជនកម្ពុជាបានធ្វើដំហានប្រវត្តិសាស្ត្រមួយ ។ តាមរយៈមធ្យោបាយផ្លូវច្បាប់ យើងកំពុងប្រឈមមុខនឹងវប្បធម៌នៃការរួចទោស និងកំពុងដើរទៅមុខនៅក្នុងដំណើរដ៏វែងរបស់យើង ដើម្បីទាមទារយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ ។ ដំណើរនេះ ទាមទារឲ្យយើងរួបរួមគ្នាជាប្រជាជាតិមួយ ។ តុលាការខ្មែរក្រហមគឺមិនមែនសម្រាប់តែយុត្តិធម៌ប៉ុណ្ណោះទេ តុលាការនេះគឺដើម្បី “ការចងចាំរបស់ជាតិយើង” ផងដែរ ។

ការវិនិច្ឆ័យទោសរបស់ ឌុច នៅថ្ងៃនេះ ផ្តល់ឱកាសមួយសម្រាប់ជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងអស់ដែលកើតក្រោយរបបខ្មែរក្រហមបានរៀនសូត្រអំពីសម័យកាលដ៏ជូរចត់ នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសយើង ពីអ្នកដែលបានជាប់ពាក់ព័ន្ធនៅក្នុងរបបនេះដ៏ផ្ទាល់ ។ អ្វីដែលបានកើតឡើងពិតប្រាកដជាមានចម្លើយលើសពីមួយ ។ ក៏ប៉ុន្តែ យើងទាំងអស់គ្នាមានកាតព្វកិច្ចចូលរួមនៅក្នុងតុលាការស្វែងរកការពិត ។ ជាមួយគ្នា យើងអាចបង្កើតឲ្យមានការយល់ដឹងឲ្យកាន់តែច្បាស់អំពីអតីតកាលរួមរបស់យើង ។

ប្រទេសកម្ពុជា គឺជាប្រទេសដែលមានរបួសយ៉ាងជ្រៅមួយក្រោយពីបានឆ្លងកាត់សង្គ្រាម និងអំពើប្រល័យពូជសាសន៍អស់រយៈពេលជាច្រើនឆ្នាំ ។ ប្រទេសយើងធ្លាប់ជាប្រទេសដែលបែកបាក់អស់រយៈពេលជាច្រើនទសវត្សរ៍ ដូច្នេះយើងទាំងអស់គ្នាមានការខ្វាយខ្វល់ដូចគ្នាចំពោះអនាគតនៃប្រទេសកម្ពុជារបស់យើង និងកេរដំណែលដែលយើងនឹងបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយ ។ ប្រទេសកម្ពុជាត្រូវការដំណើរការផ្នែកច្បាប់មួយដែលគួរឲ្យទុកចិត្តបាន ដែលជួយឲ្យយើងមានការជឿជាក់ឡើងវិញ

ទៅលើយុត្តិធម៌ ។ លើសពីនេះ យើងត្រូវការឲ្យមានដំណើរការមួយទៀតដែលជួយឲ្យយើងគិតថា យើងជាអ្នកកំណត់ប្រវត្តិសាស្ត្ររបស់ខ្លួន ។

ជនរងគ្រោះមានកាតព្វកិច្ចទទួលខុសត្រូវ និងជួយឲ្យដំណើរការរបស់តុលាការខ្មែរក្រហមទទួលបានជោគជ័យ តាមរយៈការបកស្រាយអំពីអំពើឃោរឃៅដែលខ្លួនបានទទួលនិងតាមរយៈការរៀបរាប់អំពីប្រវត្តិសាស្ត្រដែលខ្លួនបានដឹងឮ ។ ដំណើរការនេះ គឺជាជំហានទៅមុខដ៏សំខាន់មួយសម្រាប់ការព្យាបាលរបួសរបស់ជាតិយើង ។ ការផ្សះផ្សាជាតិគឺមិនមែនជាដំណើរការមួយដែលមានតែជនរងគ្រោះឬអ្នកដែលឈ្នះសង្គ្រាមតែប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវការឲ្យមានជនដៃដល់ចូលរួមថែមទៀតផង ។ អ្នកដែលធ្លាប់ធ្វើជាសត្រូវនឹងគ្នាអាចផ្សះផ្សាគ្នាបានយ៉ាងពិតប្រាកដ ប្រសិនបើភាគីទាំងពីរមានការស្មោះត្រង់នឹងគ្នា ។

ខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើយ៉ាងណាឲ្យប្រជាជនកម្ពុជាអាចចូលរួមនៅក្នុងដំណើរការកាត់ក្តី តាមរយៈការជំរុញឲ្យប្រព័ន្ធសារព័ត៌មានទូទាំងប្រទេសចាក់ផ្សាយដំណើរការកាត់ក្តីរបស់តុលាការ ។ ខ្ញុំក៏សង្ឃឹមដែរថា រាជរដ្ឋាភិបាលកម្ពុជានឹងប្រកាសឲ្យមានថ្ងៃសម្រាកជាតិមួយ ដើម្បីអនុញ្ញាតឲ្យប្រជាជនទាំងអស់ អាចចំណាយពេលមួយថ្ងៃដើម្បីយុត្តិធម៌និងការចងចាំ ។